ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សាផ្តល់ព័ត៌មាន និងការឆ្លើយតបទៅនឹងរបាយការណ៍ ស្តីពី ការប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក

ថ្ងៃព្រហស្បតិ៍ ប្រាំបីរោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីបួន ខែមករា ឆ្នាំពីរពាន់ម្ភៃបួន វេលាម៉ោងដប់បួន រសៀល នៅសាលប្រជុំខេត្តរតនៈគិរី នៃក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំពិភាក្សាផ្តល់ព័ត៌មាន និងការឆ្លើយតបទៅនឹងរបាយការណ៍ ស្តីពី ការប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានការអញ្ជើញចូលរួមពីៈ

១.ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
២.លោកជំទាវ ឡុង សុផល្លី រដ្ឋលេខាធិការក្រសួងកិច្ចការនារី
៣.លោកជំទាវ ព្រំ សុខន អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
៤.លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
៥.ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ
៦.ឯកឧត្តម ឧត្តមសេនីយ៍ទោ ទូច សម្បត្តិ អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
៧.ឯកឧត្តម ជ័យ វដ្ឋា អគ្គនាយករង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
៨.លោកជំទាវ ឧត្តមសេនីយ៍ទោ ស៊ឹម ផាណុំ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ
៩.ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ ទិត្យា ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា
១០.ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាង ជារិទ្ធ អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ

ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន និងក្រុមការងារបច្ចេកទេស សរុបចំនួន ២៨រូប ស្រី ៦រូប ។

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ស្វាគមន៍ចំពោះការអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សារបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ។ លោកជំទាវ មានប្រសាសន៍ថា កិច្ចប្រជុំនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ដែលក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរួមសហការដើម្បីរកធាតុចូលឲ្យបានគ្រប់ជ្រុងជ្រោយ ដោយការទទួលខុសត្រូវខ្ពស់ និងផ្អែកលើមូលដ្ឋានច្បាស់លាស់ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានប្រសាសន៍ថា ឆ្នាំនេះខាងក្រុមការងារវាយតម្លៃរបស់សហរដ្ឋអាម៉េរិក បានផ្ញើជាកម្រងសំណួរដើម្បីសុំជាតុចូល ដែលតម្រូវឲ្យយើងឆ្លើយដោយខ្លួនឯង ដោយឆ្នាំមុនយើងឆ្ងល់ថា សហរដ្ឋអាម៉េរិក ទទួលបានជាតុចូល ឬចម្លើយមកពីណាយកមកសរសេរដើម្បីប៉ាន់ប្រមាណវាយតម្លៃរៀងរាល់ឆ្នាំកន្លងមក? ដូច្នេះ ឆ្នាំនេះគេតម្រូវឲ្យរាជរដ្ឋាភិបាលឆ្លើយខ្លួនឯង គឺជារឿងមួយល្អដែរ ដែលមានជាកម្រងសំណួរ(Questionnaire) ត្រូវនឹងជំនាញ ឯកទេស នៃក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ យើងត្រូវពិនិត្យ និងគិតថា សំណួរណាជាជំនាញ ឬឯកទេសរបស់ក្រសួង ស្ថាប័ន អង្គភាពណា សូមឆ្លើយសំណួរនោះទៅដោយមានការពន្យល់បកស្រាយ និងមានមូលដ្ឋានច្បាស់លាស់(ឯកសារយោង) ។ ចំពោះកាលបរិច្ឆេទឈប់ទទួលរបាយការណ៍របស់អាម៉េរិក គឺត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ ដោយចាត់ទុកថាជាការវាយតម្លៃសម្រាប់ឆ្នាំ២០២៣ ដូច្នេះយើងត្រូវសហការគ្នារកចម្លើយ ពីព្រោះនេះ គឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នាក្នុងនាមរាជរដ្ឋាភិបាល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស យើងត្រូវផ្ញើចម្លើយទៅសហរដ្ឋអាម៉េរិកវិញចុងខែមករា ឆ្នាំ២០២៤ ដូច្នេះយើងនឹងជួបប្រជុំពិភាក្សាគ្នាបន្តទៀតនាពេលខ្លីខាងមុខនេះ ដើម្បីប្រមូលចម្លើយពីតាមក្រសួង ស្ថាប័ន អង្គភាពទទួលខុសត្រូវ ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ មានមតិលើកឡើងអំពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស បើឲ្យគ្រប់គ្នាធ្វើការកំណត់ គឺអត់ត្រូវទេធ្វើឲ្យប្រប្លុកប្រប្រល់ ដែលអាចនឹងមានបញ្ហានៅថ្ងៃក្រោយ បើយើងមើលសេចក្តីប្រកាសរួមរបស់អាស៊ាន(ASEAN Declaration) ឬ កិច្ចព្រមព្រៀងអាស៊ាន (ASEAN Convention) គេបានស្នើឲ្យមានអង្គភាពឯកទេសជំនាញសម្រាប់អនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំពោះកម្ពុជាយើងមាននគរបាលជំនាញ ប៉ុន្តែនៅក្នុងឯកសារទាំងពីរនេះក៏បានស្នើឲ្យមានព្រះរាជអាជ្ញាជំនាញផងដែរ យើងមិនទាន់មានទេ ក្នុងន័យនេះបើយើងអនុញ្ញាតឲ្យមានការកំណត់អត្តសញ្ញាណគ្រប់គ្នា គឺខុសទៅនឹងគោលការណ៍អាស៊ានដែលបានចែង ។ ចំពោះការកំណត់អត្តសញ្ញាណបឋមដើម្បីផ្តល់សេវា ដែលចុះហត្ថលេខាដោយ **សម្តេចក្រឡាហោម** យើងអាចយកមកអនុវត្តបាន ប៉ុន្តែការកំណត់អត្តសញ្ញាណក្នុងន័យសហរដ្ឋអាម៉េរិកសួរនេះ មានន័យថាត្រូវកំណត់តាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ពីព្រោះបើចាត់ទុកថារងគ្រោះ លុះត្រាតែរកឃើញជនល្មើស ត្រង់ចំណុចនេះសូម លោកជំទាវ ប្រធានអង្គប្រជុំ ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាពិចារណាទាំងអស់គ្នា ។ **ឯកឧត្តម** បានលើកឡើងបន្តថា ចំពោះសំណួរទាំងអស់របស់សហរដ្ឋអាម៉េរិក មានសំណួរខ្លះយល់ និងសំណួរខ្លះមិនយល់ ឬមានភាពស្រពិចស្រពិល បើមើលជាភាសាខ្មែរ ដូច្នេះពាក់ព័ន្ធបញ្ហានេះបើអាចស្នើឲ្យមានការពិភាក្សាជាមួយអ្នកវាយតម្លៃរបស់គាត់ ដូចជាការជួបជាមួយ **លោក បញ្ញា** ដើម្បីឲ្យគាត់ជួយពន្យល់យើងឲ្យបានច្បាស់ ថាតើនៅក្នុងសំណួររបស់គាត់ចង់បានអ្វី ឬព័ត៌មានអ្វីជាក់លាក់ និងចំគោលដៅ? ចំពោះអគ្គស្នងការដ្ឋាននគរបាលជាតិ មុននឹងឆ្លើយលុះត្រាណាយល់ពីសំណួរច្បាស់លាស់សិន ឆ្លើយរួចហើយត្រូវដាក់ជូនឆ្លង **ឯកឧត្តម នាយឧត្តមសេនីយ៍** អគ្គស្នងការនគរបាលជាតិ ពិនិត្យ សម្រេច ទើបបញ្ជូនមក គ.ជ.ប.ជ ។ ចំពោះកាលបរិច្ឆេទយករបាយការណ៍ជួញដូរមនុស្សដែលសហរដ្ឋអាម៉េរិកបានកំណត់ ថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ខែមីនា ឆ្នាំ២០២៤ ពេលគាត់យកពីយើង គឺយកពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ២០២៣ បន្ទាប់មកគាត់យកពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២៤ ទៀត គឺហាក់មានភាពប្រប្លុកប្រប្រល់បើធ្វើតាមគាត់ បញ្ហានេះ ឯកឧត្តម បានលើកជាសំណូមពរថា យើងគួរអញ្ជើញខាងជំនាញរបស់គាត់មកពិភាក្សា លើការដែលបានកំណត់ ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ សូមពន្យល់ឲ្យបានច្បាស់លាស់អំពីការបញ្ជូនរបាយការណ៍ទៅគាត់ ដូច្នេះសូមអង្គប្រជុំ

គិតគូរអំពីរឿងនេះផងដៀសវាងកុំឲ្យមានភាពស្មុគស្មាញ តើយើងគួរកំណត់ចាប់ពី ថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ឬ ពីថ្ងៃទី៣១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤? ។ បញ្ហាមួយទៀត គឺការលើកយកមាត្រាមកផ្ដន្ទាទោស យើងគួរជជែកពិភាក្សាផងដែរ ពីព្រោះគាត់បានលើកយកចំនួន១២មាត្រាមកនិយាយ ក្នុងចំណោម៥៤មាត្រា ដូច្នេះសូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ពិនិត្យ និងស្នើឲ្យគាត់ពិនិត្យកែសម្រួលឡើងវិញ អំពីការចោទប្រកាន់ស្រមតាមទិដ្ឋភាព នៃច្បាប់ជាតិរបស់យើង ដូចជាការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ឃើញថាគាត់សរសេរមានការពាក់ព័ន្ធច្រើន ប៉ុន្តែក្នុងចំណោម១២មាត្រាដែលគាត់យកមកប្រើ គឺមិនមានពាក់ព័ន្ធនឹងការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញទេ ធ្លាប់បានលើកយកបញ្ហានេះពិភាក្សាជាមួយ លោក **បញ្ញា** ចំនួន២ដងរួចមកហើយ ប៉ុន្តែគាត់បានឆ្លើយជាលក្ខណៈបច្ចេកទេសថា គេមិនបានកំណត់ឲ្យប្រើប្រាស់តែមាត្រាទាំង១២នេះនោះទេ គឺគេឲ្យយកមាត្រាណាដែលទាក់ទងនឹងបទល្មើសជួញដូរមនុស្ស និងបទល្មើសរំលោភបំពានលើកុមារ ការឆ្លើយរបស់គាត់ មានន័យថាយើងរត់តាមគាត់រហូត យើងចង់ឲ្យគាត់កំណត់ឲ្យបានច្បាស់លាស់អំពីមាត្រានីមួយៗដែលត្រូវយកមកប្រើប្រាស់សម្រាប់ផ្ដន្ទាទោស នៃអំពើជួញដូរមនុស្ស បើយើងមិនតស៊ូមតិជាមួយគាត់ទេ គឺអ្វីដែលយើងបានធ្វើចេញជាលទ្ធផលគាត់មិនបានយកទៅដាក់បញ្ចូលទេ ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានប្រសាសន៍ពាក់ព័ន្ធការកំណត់អត្តសញ្ញាណជនរងគ្រោះ យើងអាចពន្យល់ទៅគេបានអ្វីដែលយើងបានធ្វើកន្លងមក ពីព្រោះគោលការណ៍ណែនាំរបស់យើង គឺមានគោលបំណងចង់រកឲ្យឃើញថាគាត់ជាជនរងគ្រោះ ឬអាចជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវា ប៉ុន្តែទីបំផុតយើងនៅតែយកកំណត់ហេតុរបស់នគរបាលជាមូលដ្ឋានសម្រាប់ដាក់បន្ទុកជនល្មើសដដែល ដូច្នេះការកំណត់អត្តសញ្ញាណនៅមានការយល់ច្រឡំ និងមិនច្បាស់លាស់ ពីព្រោះកន្លងមកបើយើងរង់ចាំការវាយតម្លៃពីនគរបាល ឬតុលាការ គឺជនរងគ្រោះពុំទទួលបានសំណាងអ្វីទាំងអស់ ឥឡូវនេះយើងបានឯកភាពគ្នាជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួចហើយថាការកំណត់អត្តសញ្ញាណ គឺត្រូវប្រគល់ជូននគរបាលជំនាញ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចំណែកខាងសង្គមកិច្ច គឺជាអ្នកចូលរួមតាមដានលទ្ធផលដើម្បីផ្ដល់សេវាដែលបានកំណត់ ឬតាមនីតិវិធីរបស់សង្គមកិច្ច ហើយយើងទទួលបានទិន្នន័យតែមួយ ចំពោះគោលការណ៍ណែនាំនេះ ក៏ត្រូវពិនិត្យលទ្ធភាពដើម្បីកែលម្អប្រសិនបើមានការចាំបាច់ ឬខុសបច្ចេកទេសណាមួយ ប៉ុន្តែបើនគរបាលយុត្តិធម៌ទទួលយក គឺយើងមិនមានការកែប្រែទៀតទេ ចំពោះអ្នកផ្ដល់សេវាភាគច្រើនគាត់នឹងមានការសាកសួរបន្ថែមទៀត ដើម្បីកាន់តែច្បាស់ប៉ុន្តែមិនមែនជាការកំណត់អត្តសញ្ញាណទេ ឬសាកសួរថា តើគាត់ចង់បានសេវាអ្វីខ្លះក្នុងពេលដំណើរការរឿងក្ដី? ដូច្នេះ យើងនឹងធ្វើការពិភាក្សាគ្នាលើគោលការណ៍ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានច្បាស់លាស់ ។ ចំពោះកាលបរិច្ឆេទយករបាយការណ៍ ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និង ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២៤ តើយើងគួរជ្រើសរើសយកមួយណា? **លោកជំទាវ** បញ្ជាក់ថា ធ្លាប់បានពិភាក្សាជាមួយខាងសហរដ្ឋអាម៉េរិករួចហើយ ចំពោះការផ្ដល់របាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ បើគិតមើល គឺមានរយៈពេលមួយឆ្នាំដូចគ្នា ។ លោកជំទាវ មានប្រសាសន៍បញ្ជាក់ថាជួនកាលកន្លងមកចំពោះរបាយការណ៍របស់យើង គឺយើងមិនបានចែកឲ្យដាច់ ១ឆ្នាំមាន៤ត្រីមាស ហើយគេយកពីត្រីមាសទី២(ពីថ្ងៃទី០១ ខែមេសា) ដល់ត្រីមាសទី៤(ថ្ងៃទី៣១ ខែធ្នូ) ឆ្នាំ២០២៣ ដល់ត្រីមាសទី១(ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា)ឆ្នាំ២០២៤ ពេលខ្លះយើងត្រូវតាមគេខ្លះ ពីព្រោះគេជាអ្នកដាក់ពិន្ទុ និងវាយតម្លៃ

បើគេតម្រូវឲ្យយើងធ្វើដែលគិតថាមិនប៉ះពាល់អ្វីទេ យើងគួរធ្វើទៅ ដូចជាការកំណត់កាលបរិច្ឆេទ នៃការយករបាយការណ៍ជួញដូរមនុស្សពីកម្ពុជា ហើយកម្ពុជាយើងតែងតែធ្វើរបាយការណ៍កំណត់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល ដែលយើងគិតថារបាយការណ៍ប្រចាំឆ្នាំ(១ឆ្នាំ) ដូច្នេះយើងគួរយកតាមគេកំណត់ គឺ (៣ត្រីមាសឆ្នាំចាស់ និងត្រីមាសទី១ឆ្នាំថ្មី) ហើយយើងនៅមានពេលវេលាសម្រាប់ធ្វើការងារនេះផងដែរ បើយើងឲ្យគេតម្រូវតាមយើង គឺគេពិបាកក្នុងការតម្រូវតាមយើងបន្តិច ដូច្នេះយើងត្រូវរកការឯកភាពគ្នាសិន មុននឹងទៅពិភាក្សាជាមួយគេ ។ មួយទៀតពាក់ព័ន្ធបញ្ហាការ វាយតម្លៃ នៃការចោទប្រកាន់តាមមាត្រាច្បាប់ **លោកជំទាវ** មានប្រសាសន៍ឯកភាពលើការលើកឡើងរបស់ ឯកឧត្តម អគ្គស្នងការរង ដោយយកតាមច្បាប់ជាតិ គឺមិនតម្រូវយកតាមច្បាប់អាម៉េរិកទេ ច្បាប់ជាតិយើងមានប៉ុណ្ណា គឺយើងចោទប្រកាន់គេប៉ុណ្ណឹង ។

**ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ាង ធារិទ្ធ** អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ មានមតិលើកឡើងពាក់ព័ន្ធការឆ្លើយសំណួររបស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា គួររៀបចំយុទ្ធសាស្ត្រច្បាស់លាស់ បើយើងមិនមានការរៀបចំយុទ្ធសាស្ត្រទេនឹងអាចមានផលពិបាក និងឈានដល់ការទទួលខុសត្រូវនាថ្ងៃមុខទៀត ពីព្រោះចម្លើយនេះ គឺជាចម្លើយសម្រាប់ការវាយតម្លៃដាក់ពិន្ទុក្នុងខែមិថុនា យើងដឹងហើយថាកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ៣ ចំនួន២ឆ្នាំជាប់គ្នា បើនៅតែទទួលចំណាត់ថ្នាក់លេខ៣ដដែលបែបនេះ នោះកម្ពុជាអាចនឹងជួបបញ្ហានូវការដាក់ទណ្ឌកម្ម ដូច្នេះ យើងគួរតែពិនិត្យមើលថា ហេតុអ្វីបានជាសហរដ្ឋអាម៉េរិកដាក់កម្រងសំណួរជាច្រើនបែបនេះ? គឺជាសក្ខីកម្មក្នុងការវាយតម្លៃក្នុងខែមិថុនាខាងមុខនេះ បើសហរដ្ឋអាម៉េរិកមិនដាក់កម្រងសំណួរដាក់លាក់មកទេ កម្ពុជានឹងមិនទទួលយកបន្តទៀត ។ **ឯកឧត្តម ឧត្តមសេនីយ៍ឯក** មានមតិបន្តថា ការដាក់សំណួរជាច្រើនរបស់សហរដ្ឋអាម៉េរិកមកកម្ពុជា មានសំណួរមួយចំនួនពាក់ព័ន្ធនឹងក្រសួង ស្ថាប័នច្រើន ដូច្នេះសហរដ្ឋអាម៉េរិកពុំទាន់ស្គាល់កម្ពុជាច្បាស់លាស់ទេ គឺសំដៅលើរចនាសម្ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់កម្ពុជានៅឡើយ ការចេញសំណួររបស់គាត់ធ្វើឲ្យយើងមានការភាន់ច្រឡំ យើងមិនដឹងថាគេខុស ឬយើងត្រូវនោះទេ យើងចាំបាច់ត្រូវតែឆ្លើយ បើយើងមិនឆ្លើយនឹងមានបញ្ហាមិនខាន ហើយការឆ្លើយរបស់យើង គឺក្នុងនាមម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់ ។ ចំពោះការឆ្លើយតបសំណួរខាងលើនេះ យើងគួរតែពិនិត្យមើលសំណួរនីមួយៗឲ្យបានច្បាស់លាស់ ហើយធ្វើការប្រគល់ជូនក្រសួង ស្ថាប័ន អង្គភាពជំនាញធ្វើការឆ្លើយ និងផ្តល់ព័ត៌មានមកវិញ មានន័យថាធ្វើយ៉ាងណាគ្រប់សំណួរត្រូវមានម្ចាស់ដែលជាក្រសួង ស្ថាប័ន អង្គភាពជំនាញ ហើយត្រូវសិក្សាឲ្យយល់ច្បាស់អំពីសំណួររបស់គាត់មុននឹងឆ្លើយតបទៅគេ យើងមិនអាចឆ្លើយឲ្យតែរួចបានទេត្រូវគិតនូវលទ្ធផល ការឆ្លើយយករួចខ្លួន ឬឆ្លើយយកត្រូវតែឯង គឺមិនអាចចេញជាលទ្ធផលល្អនោះទេសម្រាប់យើងទាំងអស់គ្នា ចំពោះសំណួរណាមិនយល់យើងគួរស្នើសុំឲ្យមានការពន្យល់ពីភាគីអាម៉េរិកដូច ឯកឧត្តម អគ្គស្នងការរង បានលើកឡើង ហើយគេក៏មិនមានពេលពន្យល់គ្រប់សំណួរទាំងអស់បានទេ គឺឆ្ងល់ត្រង់ណាសួរត្រង់ហ្នឹង ត្រង់ណាឆ្លើយបានយើងឆ្លើយ ដូច្នេះសូម ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន អង្គភាពមេត្តាពិនិត្យមើលកម្រងសំណួរ តើសំណួរណាមួយពាក់ព័ន្ធជាមួយក្រសួង ស្ថាប័ន អង្គភាពរបស់ខ្លួន? ត្រូវចំណាំឲ្យបានច្បាស់ដើម្បីត្រៀមលក្ខណៈទុកជាមុន ។ **ឯកឧត្តម** បានធ្វើការស្នើសុំឲ្យមានអ្នកទំនាក់ទំនង រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយសហរដ្ឋអាម៉េរិក ដើម្បីជួយសម្របសម្រួលលើការងារនេះ ដូចជាភាពមិនទាន់ច្បាស់លាស់ចំពោះសំណួរណាមួយ យើងអាចធ្វើការទំនាក់ទំនងទៅគេបាន ឬ គ.ជ.ប.ជ ជាអ្នកសម្របសម្រួល ។ ចំពោះកាលបរិច្ឆេទការយករបាយការណ៍ សម្រាប់កម្ពុជា គឺគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពីព្រោះ

គឺជារបៀបរបបការងាររបស់កម្ពុជា ចំពោះការកំណត់យកពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ គឺយើងមានគុណសម្បត្តិមួយផ្សេងទៀតបើយើងធ្វើបាន ។ **ឯកឧត្តម** បានលើកឡើងថា សំណួរទាំងអស់នេះ សហរដ្ឋអាម៉េរិកនឹងយកទៅផ្ទៀងផ្ទាត់ជាមួយអនុសាសន៍ទាំង១៧ចំណុច ក្នុងឆ្នាំ២០២២មិនខាន បើយើងឆ្លើយមិនច្បាស់លាស់ ឬកុហកត្រង់ចំណុចណាមួយ គឺមិនអាចទៅរួចទេ នេះគឺជាការដកពិសោធន៍ពាក់ព័ន្ធការងារលាងសម្អាតប្រាក់ គេនឹងឲ្យយើងពន្យល់គ្រប់ផ្នែក គ្រប់ចំណុចដែលយើងបានឆ្លើយទៅគេ ដែលគេមើលឃើញថាមិនសមហេតុផល ដូច្នេះរបាយការណ៍ឬចម្លើយណាមួយដែលមានចរិតភូតកុហក ឬមិនសមហេតុផលតាមការចង់បាន គឺគេទម្លាក់យើងចោល ។ ដើម្បីជាយុទ្ធសាស្ត្រ៖ គួរមានការឯកភាពគ្នាសិន តើក្នុងអំឡុងពេលណាមួយដែលយើងគួរយកមកឆ្លើយឲ្យបានច្បាស់លាស់ និងមានភាពម្ចាស់ការ? ពីព្រោះយើងមិនអាចរកជាតុចូល ឬឆ្លើយនឹងសំណួរទាំងអស់នេះបានទេ ដោយយោងតាមពេលវេលាយើងមានរយៈពេលខ្លីផងនោះ ហើយត្រូវគិតអំពីភាពខ្លាំងរបស់យើងជាមុនសិន បើយើងមានភាពខ្លាំងភូមិសាស្ត្រនយោបាយនឹងត្រូវឃ្លាតឆ្ងាយ បើយើងមិនច្បាស់លាស់ទេ នោះគេនឹងយកបញ្ហាភូមិសាស្ត្រនយោបាយមកគ្របយើងជាមិនខាន ។

**លោកជំទាវ** ប្រធានអង្គប្រជុំ មានប្រសាសន៍ឲ្យដឹងថា ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ខាងស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជានឹងមកជួបពិភាក្សា សំណេះសំណាលជាមួយ **ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មុននឹងជួបជាមួយ ឯកឧត្តមអភិសន្តិបណ្ឌិត គេបានសុំជួបជាមួយ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** នៅមិនទាន់ដឹងថាគេចង់ពិភាក្សាពីរឿងអីនោះទេ ដូច្នេះឆ្លៀតក្នុងឱកាសនោះបើយើងមិនមានបំណងពិភាក្សារឿងសំណួរ គឺយើងអាចស្នើសុំជួបជាមួយអ្នកបច្ចេកទេសដើម្បីឲ្យពន្យល់បន្ថែមបាន ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា កាលបរិច្ឆេទ នៃការប្រមូលចម្លើយ គឺសុំត្រឹមចុងខែមករា ហើយសូមឲ្យក្រសួង ស្ថាប័ន អង្គភាពដែលជាម្ចាស់សំណួរប្រគល់ចម្លើយក្នុងរយៈពេល ១០ថ្ងៃ ឬ២សប្តាហ៍ក្រោយកិច្ចប្រជុំនេះ ដើម្បីមានពេលពិនិត្យកែសម្រួល ផ្ទៀងផ្ទាត់ បើយើងឆ្លើយនៅពេលនេះក៏មិនបានគ្រប់ជ្រុងជ្រោយដែរ ពីព្រោះត្រូវការចូលរួមពីក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធមួយចំនួនទៀត ដូចជាក្រសួងយុត្តិធម៌ តុលាការ អយ្យការ កងរាជអាវុធហត្ថ... ត្រូវរកការឯកភាពគ្នា ពីព្រោះសហរដ្ឋអាម៉េរិកនឹងសួរដេញដោលពីមួយទៅមួយ យើងនឹងឆ្លើយខុសគ្នា ។

**លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ **ប្រធានអង្គប្រជុំ** មានប្រសាសន៍បូកសរុបលទ្ធផល នៃកិច្ចប្រជុំដោយមានការឯកភាពគ្នា៖

ទី១.សូមព្យាយាមឆ្លើយតាមសំណួរដែលសហរដ្ឋអាម៉េរិកដាក់មក ដោយពិនិត្យមើលសំណួរណាពាក់ព័ន្ធជាមួយក្រសួង ស្ថាប័ន អង្គភាពណា សូមឆ្លើយសំណួរនោះទៅ ចំពោះក្រសួង ស្ថាប័ន អង្គភាពដែលមិនមានឈ្មោះ ឬពាក់ព័ន្ធនឹងសំណួរនេះទេ បើដឹងរឿងសូមជួយឆ្លើយ និងផ្តល់ព័ត៌មានមកផង ។

ទី២.កំណត់យកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ ជួបប្រជុំពិភាក្សាគ្នា និងផ្តល់ព័ត៌មានពាក់ព័ន្ធសំណួរពីបណ្តាក្រសួង ស្ថាប័ន អង្គភាពដែលជាម្ចាស់សំណួរ ។

ទី៣.ពិភាក្សាឲ្យបានជាក់លាក់អំពីកាលបរិច្ឆេទ នៃការកំណត់ប្រគល់របាយការណ៍ជួញដូរមនុស្សទៅសហរដ្ឋអាម៉េរិក តើគួរយកពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ឬយកពីថ្ងៃទី០១ មេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤?

ទី៤.ពាក់ព័ន្ធផ្នែកច្បាប់សូមប្រគល់ជូន **ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** អគ្គស្នងការរងនគរបាលជាតិ ដឹកនាំពិភាក្សា ។

ចុងបញ្ចប់ នៃកិច្ចប្រជុំ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍បញ្ជាក់ជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា អង្គប្រជុំជ្រាបថា គ្រប់ក្រសួង ស្ថាប័ន អង្គភាពដែលពាក់ព័ន្ធនឹងសំណួរសូមរកចម្លើយ និងយកមកប្រជុំពិភាក្សាគ្នានៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ ហើយធ្វើការពិភាក្សា កែសម្រួល និងសម្រេច ចំពោះចម្លើយនីមួយៗមិនមែនឆ្លើយឲ្យតែរួចខ្លួនទេ គឺឆ្លើយលក្ខណៈជាយុទ្ធសាស្ត្រ ដើម្បីដោះបន្ទុកពីលេខ៣ ដែលកម្ពុជាទទួលបាន២ឆ្នាំជាប់គ្នា ប្រសិនទទួលបានលេខ៣ឆ្នាំនេះទៀត គឺប្រឈមនឹងការដាក់ទណ្ឌកម្មណាមួយមិនខាន ។

កិច្ចប្រជុំពិភាក្សា ផ្តល់ព័ត៌មាន និងការឆ្លើយតបទៅនឹងរបាយការណ៍ ស្តីពី ការប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ របស់ក្រសួងការបរទេសសហរដ្ឋអាម៉េរិក បានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំមួយ និងម្ភៃនាទីល្ងាច ថ្ងៃខែឆ្នាំដដែល ។

ថ្ងៃចន្ទ ១២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ឯក សៅ ស៊ីនួន

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃចន្ទ ១២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ
08/01/24